# តើទិន្នន័យបើកចំហជាអ្វី?



វាជាទិន្នន័យដែលបង្កើតឡើងដោយស្ថាប័នរដ្ឋ វិស័យឯកជន អ្នកស្រាវជ្រាវ ឬប្រជាពលរដ្ឋដែលគ្រប់គ្នាអាចយកមកប្រើប្រាស់បានក្នុងគោលបំណងអ្វីក៏ដោយ ដោយគ្មានការហាមឃាត់។

អ្នកសារព័ត៌មានជាអ្នកជ្រើសរើសថាព័ត៌មានអ្វីសំខាន់ដែលត្រូវចែករំលែក។







ប្រជាពលរដ្ឋចូលរួមក្នុងការផ្តល់យោបល់លើគោលនយោបាយ ហើយទាមទារគណនេយ្យភាពពីស្ថាប័នរដ្ឋ និងវិស័យឯកជន។

# ការអង្កេតអំពីទិន្នន័យបើកចំហ



មានអ្នកផលិតនិងប្រើប្រាស់ទិន្នន័យជាច្រើន។



“ប្រព័ន្ធទ្រទ្រង់” ទិន្នន័យបើកចំហដែលមានដំណើរការល្អត្រូវការ “ការផ្គត់ផ្គង់” និង “តម្រូវការ” ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសមស្រប។



ក្រុមការងារសិក្សារឿងទិន្នន័យបើកចំហបានពិនិត្យមើលទិន្នន័យដែលត្រូវបានផលិតនៅក្នុងប្រទេសកម្ពុជានិងរបៀបដែលវាត្រូវបានប្រើប្រាស់។

ប្រទេសកម្ពុជាមានតម្រូវការខ្លាំង។ មានតែ ២០ ភាគរយនៃអ្នកឆ្លើយតបប៉ុណ្ណោះដែលផលិតទិន្នន័យ។ មានមនុស្សតិចណាស់ដែលចែករំលែកទិន្នន័យ។









សាកលវិទ្យាល័យនានាបាន
ប្រមូលទិន្នន័យ ប៉ុន្តែមានតិច
តួចប៉ុណ្ណោះដែលចែកចាយវា។

អង្គការសង្គមស៊ីវិលផលិតទិន្នន័យ
ភាគច្រើនសម្រាប់តែការប្រើប្រាស់
ផ្ទៃក្នុងរបស់គម្រោង។

ប្រភពរដ្ឋាភិបាលច្រើនតែផ្ដល់ជាព័ត៌មាន
ប៉ុន្តែពុំសូវផ្ដល់ជាទិន្នន័យដើមនោះទេ។

រដ្ឋាភិបាលពុំបានធ្វើមជ្ឈការទិន្នន័យច្រើននោះទេ។

ទិន្នន័យបើកចំហនៅកម្ពុជាត្រូវបានប្រើប្រាស់
ជាចម្បងសម្រាប់ការសិក្សាស្រាវជ្រាវ ការធ្វើ
របាយការណ៍ និងការអនុវត្តគម្រោង។





អ្នកសារព័ត៌មានភាគច្រើនមិនសូវយល់ដឹងពីការប្រើប្រាស់ទិន្នន័យសម្រាប់សរសេរព័ត៌មាននោះទេ។



មានអ្នកឆ្លើយសំណួរតិចតួចណាស់ដែលយល់
ដឹងពីអ្វីដែលជា "ទិន្នន័យបើកចំហ" និង
"អត្តទិន្នន័យ"

វត្តមានទិន្នន័យបើកចំហច្រើនបន្ថែម
ទៀតនឹងផ្តល់នូវការវាស់វែងកាន់តែ
ច្បាស់អំពីសមិទ្ធផលរបស់ប្រទេស
កម្ពុជាលើបញ្ហាអភិវឌ្ឍន៍។







ប្រទេសជាច្រើននៅអាស៊ានកំពុងផ្តល់ការយកចិត្តទុក
ដាក់ខ្លាំងរឿងទិន្នន័យបើកចំហ និងបង្កើនការវិនិយោគ
លើហេដ្ឋារចនាសម្ព័ន្ធទិន្នន័យរបស់ពួកគេ។ តើកម្ពុជា
នឹងអនុវត្តដូចប្រទេសទាំងនោះដែរឬទេ ? គម្រោងដែល
នឹងត្រូវអនុវត្តមួយចំនួនហាក់ដូចជាផ្តល់ក្តីសង្ឃឹមខ្លះៗ
លើរឿងនេះ។